ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមេសា ឆ្នាំ២០១៧

នៅក្នុងខែមេសា ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងសម័យប្រជុំពេញអង្គលើកទី១០ ព្រឹទ្ធសភានីតិកាលទី៣ចំនួន០១លើក

-អញ្ជើញទទួលព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា **និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលបានយាងនិវត្តមកដល់មាតុប្រទេសវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-អនុញ្ញាតឲ្យឯកឧត្តម **ង្វៀន សួនហ៊ុក** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម និងសវនាការ

-ទទួលសារតាំងពីឯកឧត្តម Kreso Glavac ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋក្រូអាស៊ី

-អនុញ្ញាតឲ្យឯកឧត្តម **ឧត្តមសេនីយ៍ទោ** VO MINH LOUNG សមាជិកមជ្ឈឹមបក្សកុម្មុយនីស្តវៀតណាម មេបញ្ជាការយោធភូមិភាគ៧ និងគណៈប្រតិភូបញ្ជាការយោធភូមិភាគ៧ ក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម និងសវនាការ

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខមន្ត្រីរាជការ ដែលបម្រើការងារនៅពុទ្ធសាសនបណ្ឌិត ព្រមទាំងជូនពរឆ្នាំថ្មីចំពោះនិវត្តជនជាមន្ត្រីនគរបាលចរាចររាជធានីភ្នំពេញចំនួន៤១រូប

-អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរ គណៈចលនាសាសនិកឥស្លាម ព្រមទាំងក្រុមគ្រូពេទ្យ និងនិស្សិតពេទ្យស្ម័គ្រចិត្តចំនួន២៧០នាក់ ដែលបានចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំពារាម ស្រុកបាទី ខេត្តតាកែវ

-អញ្ជើញជាអធិបតី ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់កុដិសាលាអនុគណខណ្ឌច្បារអំពៅ និងពិធីស្រោចស្រពសុគន្ធវារីប្រគេនព្រះញាណវង្ស **សៅរ៍ មុនី** ព្រះរាជាគណៈថ្នាក់ត្រីវត្តកំសាន្ត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-ប្រារព្ធពិធីបុណ្យស្រោចស្រពសុគន្ធវារីបច្ច័យបួនគោរពជូនមាតា បិតា លោកឪពុកធំ ម្តាយធំ និងអបអរសាទរទេវតាឆ្នាំថ្មី

-អញ្ជើញជាអធិបតីក្នុងពិធីបង្សុកូលជូនមាតា បិតា និងញាតិការទាំង៧សណ្តាន នៅភូមិកណ្តាលកោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធព្រះវិហារ និងសមិទ្ធផលនានា ក្នុងវត្តអង្គបឹងចេក ភូមិអង្គបឹងចេក សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខក្រុមគ្រួសារសព ឯកឧត្តម **ពិត តាំងសាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅសង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

-អញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសពឧបាសិកា **ទា លីហួង** ដែលត្រូវជាម្តាយលោកឧកញ៉ា **ឡាយ ប៊ុនប៉ា** នៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមក្នុងពិធីបុណ្យសព ពិធីបូជា និងពិធីបុណ្យគម្រប់៧ថ្ងៃសព លោក **សាយ សុផល** ជំនួយការផ្ទាល់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** នៅរាជធានីភ្នំពេញ

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៦៥ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៦៥ និងទទួលសំណើរាជរដ្ឋាភិបាលចំនួន៦៥

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២១ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉ំណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្ដីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គលើកទី១០ព្រឹទ្ធសភា នីតិកាលទី៣ ចំនួន០១លើក

-អនុញ្ញាតឲ្យឯកឧត្តម **ឆិន ឆាងជី** (H.E.Mr Chen changzhi) អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សភាប្រជាជនទូទាំងប្រទេស នៃសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្ដែងការគួរសម

-អញ្ជើញចូលរួមក្នុងពិធីសូត្រមន្ត ប្រោះព្រំសុំសេចក្ដីសុខ និងអបអរសាទពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៦៤ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងសម័យប្រជុំពេញអង្គលើកទី១០ព្រឹទ្ធសភា នីតិកាលទី៣ចំនួន០១លើក

-អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងខេត្តកណ្ដាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និបាតកោះពេជ្រ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងាររវាងក្រុមមិត្តភាពកម្ពុជា ចិន ជាមួយវិនិយោគិន នៅសមាគមក្រុមមិត្តភាពកម្ពុជា ចិន

-អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយក្រុមប្រឹក្សាឃុំទាំង១០ ក្នុងស្រុកកោះធំ ព្រមទាំងទូទាំងស្រុកលើកដែក ស្រុកកៀនស្វាយ ស្រុកកណ្ដាលស្ទឹង ស្រុកស្អាង និង ក្រុងតាខ្មៅ ខេត្តកណ្ដាល

-អញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្ត និងជប់លៀងអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដើម្បីប្រោះព្រំសុំសេចក្ដីសុខ និងសិរីសួស្ដី វិបុលសុខគ្រប់ប្រការជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សាលាពុទ្ធិកបឋមសិក្សា និងសមិទ្ធផលនានាក្នុងវត្តយសមេត្រី ស្ថិតក្នុងឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល

-អញ្ជើញចូលរួមបុណ្យគម្រប់ខួប១០០ថ្ងៃ ឧទ្ទិសកុសលជូន **សម្តេចស៊ីសុវត្ថិ ជីវ័ន្ត មុនីរ័ក្ស** អតីតអនុប្រធានទី១ ព្រឹទ្ធសភា នៅវត្តបទុមវតី

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ពិត តាំងសាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

-អញ្ជើញនាំយកទេយ្យទាន ដើម្បីរៀបចំពិធីបង្សុកូលឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធ លោកជំទាវ **ភូ ធឿន** និងបុព្វការីជន ដែលបានពលីជីវិតក្នុងការរំដោះ និងការកសាងប្រទេសជាតិ នៅវត្តប្រាំបីមុំ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៣៥ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក:**

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៤ ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមរដ្ឋាភិបាល នៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

៣.កំណត់កាលបរិច្ឆេទ និងរបៀបវារៈបន្តសម័យប្រជុំលើកទី១០ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.កិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក**

១.ពិនត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

២.ពិនិត្យ និងឲ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមរដ្ឋាភិបាល នៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមេសានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាម តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយតំណាងរាជរដ្ឋាភិបាល និងក្រុមតំណាងរាស្ត្រហត្ថលេខី ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីស្នើច្បាប់ចំនួន០១ និងសេចក្ដីព្រាងច្បាប់ចំនួន០១ ។

**៤.២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់អំពី ៖

១.របៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅថ្នាក់ឃុំ សង្កាត់នៃខេត្តកំពង់ចាម

២.របៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ផ្ដោតលើមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង របៀបដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដីស្រុក ក្រុង និងការដោះស្រាយវិវាទផ្សេងៗ ព្រមទាំងការចូលរួមអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌក្នុងវង្វង់ដែនសមត្ថកិច្ច

៣.ការអនុវត្តច្បាប់ និងរបៀបដោះស្រាយទំនាស់ដែលថ្នាក់ស្រុក ក្រុង បញ្ជូនមកថ្នាក់ខេត្ត ការងារផ្សព្វផ្សាយច្បាប់ និងការងារនីតិកម្ម ព្រមទាំងការចូលរួមអនុវត្តក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌក្នុងវង្វង់ដែនសមត្ថកិច្ច

៤.ការអនុវត្តក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីរបស់សាលាដំបូងខេត្តកំពង់ចាម និងសកម្មភាពការងាររបស់មន្ត្រីនគរ

បាលយុត្តិធម៌ចំពោះការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងកិច្ចការងារជាមួយសាលាដំបូងខេត្ត និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

**៤.៣.មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០១ករណី ទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០៩ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី និងបានឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៣នាក់

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បើកកិច្ចប្រជុំដើម្បីរៀបចំផែនការបេសកកម្មឈ្វេងយល់អំពីការអនុវត្តភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងបញ្ហាប្រឈមនានា

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បើកកិច្ចប្រជុំដើម្បីត្រៀមចូលរួមសន្និបាតបូកសរុបក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ របស់ខេត្តកោះកុង

-ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា បារាំង បើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារការបរទេសឆ្នាំ២០១៦ និងលទ្ធផលនៃការរៀបចំទិវាភាសាបារាំង

-អញ្ជើញជួបប្រជុំជាមួយសមាជិក សមាជិកាដែលជាគណៈប្រតិភូសម្រាប់ត្រៀមចូលរួមប្រជុំមហាសន្និបាតអន្តរសហសភា IPU ស្តីពីសិទ្ធិមនុស្ស នៅប្រទេសបង់ក្លាដេស

-អញ្ជើញចូលរួមបំភ្លឺតវ៉ាលើការសម្រេចរបស់មហាសន្និបាត ស្តីពីបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា នៅប្រទេសបង់ក្លាដេស

-អញ្ជើញចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាមួយសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ខេត្តព្រៃវែងស្តីពី ជំរុញស្ត្រីចូលរួមជ្រើសរើសអ្នកដឹកនាំឃុំ សង្កាត់

-អញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី៣ លើសេចក្តីព្រាងបឋមច្បាប់ស្តីពី ការការពារសាក្សី និងច្បាប់ស្តីពី ការការពារបុគ្គលរាយការណ៍ នៅអង្គភាពប្រឆាំងអំពើពុករលួយ

-អញ្ជើញជួបពិភាក្សាការងារ និងស្តាប់បទបង្ហាញរបស់តំណាងវិទ្យាស្ថានសភាកម្ពុជា (PIC)

-អនុញ្ញាតឲ្យសិស្សានុសិស្សចំនួន១៣នាក់ និងលោកគ្រូចំនួន០៣នាក់ នៃសាលាបឋមសិក្សាឫទ្ធី៩ ស្ថិតនៅឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចូលជួបសំណេះ

សំណាល និងបានផ្តល់អនុសាសន៍ល្អៗមួយចំនួន មុនពេលដែលចូលប្រកួតកីឡា Baseball នៅរមណីយដ្ឋានបឹងសំរិទ្ធ ខេត្តកំពង់ធំ

-អញ្ជើញចូលរួមជួបសំណេះសំណាលជាមួយក្រុមយុវជនរាជធានីភ្នំពេញ នៅសាលមហោស្រពកោះពេជ្រ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន២០៨លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះ ពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៧លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ជា ជេដ្ឋ** អញ្ជើញដឹកនាំគណៈប្រតិភូសមាជិកព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើប្រាស់ភាសាបារាំង (APF) នៅទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **យ៉ង់ សែម** និងលោកជំទាវ **ពុំ ស៊ីចាន់** អញ្ជើញចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភាIPU លើកទី៣៦ នៅទីក្រុងដាកា ប្រទេសបង់ក្លាដេស

-អនុញ្ញាតឲ្យឯកឧត្តម **វ៉ា វុត្ថា៉** អតីតប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលក្រុងកែប បច្ចុប្បន្នជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំប្រតិភូជនជាតិកូរ៉េ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធទៅនឹងការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារសាធារណរដ្ឋកូរ៉េ

-អនុញ្ញាតឲ្យឯកឧត្តម PRASITH SAYASITH ឯកអគ្គរដ្ឋទូតឡាវប្រចាំនៅកម្ពុជា ចូលជួបសំណេះសំណាលការងារ និងជូនពរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឡាវ

-អនុញ្ញាតឲ្យឯកឧត្តមអគ្គកុងស៊ុលឡាវ នៅខេត្តស្ទឹងត្រែង និងសហការី ចូលជួបសំណេះសំណាល និងជូនពរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឡាវ នៅក្រុងបានលុង ខេត្តរតនគិរី

-អនុញ្ញាតឲ្យលោកស្រី Alicia Corredera Morales អនុប្រធាននៃវិទ្យាស្ថានគុយបាដើម្បីមិត្តភាពរបស់ប្រជាជន ចូលជួបពិភាក្សាការងារ និងសម្តែងការគួរសម ៗ/.

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៧

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**តេព ងន**

ចម្លងជូនៈ
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ